ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តបន្ទាយមានជ័យ

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ ១៩៨

ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៨

សាលក្រមលេខ : ០១ "ឈ"/ ១៨

ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២០

## ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ក្រឡាបញ្ជី

-កញ្ញា [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

**ដើមចោទ**

ឈ្មោះ [redacted] ចាវ ភេទស្រី កើតថ្ងៃទី ២០ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ។

អាសយដ្ឋាន ៖ [redacted] ។

**មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ**

លោក [redacted] សុផល អត្តលេខ ៣២៤

ការិយាល័យមេធាវី ៖ ព្រះច័ន្ទ

អាសយដ្ឋានការិយាល័យមេធាវី ៖ [redacted] ។

**ចុងចម្លើយ**

ឈ្មោះ [redacted] សុងហ៊ី ភេទប្រុស កើតថ្ងៃទី ១៥ ខែមីនា ឆ្នាំ១៩៧០ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ។

អាសយដ្ឋាន ៖ [redacted] ។

**សហមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ**

១.លោកស្រី [redacted] ចាន់ថា អត្តលេខ ១៣៧៨ ។

អាសយដ្ឋានការិយាល័យមេធាវី ៖ [redacted] ។

២.លោកស្រី [redacted] តុលាផុស អត្តលេខ ៨០៥ ។

៣.លោក [redacted] លាន អត្តលេខ ២១៩២T

អាសយដ្ឋានការិយាល័យមេធាវី ៖ [redacted] ។

## អង្គហេតុ និង ចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយភាគី

#### ក.១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១-សុំផ្ដាច់អនីតិសង្វាសពីចុងចម្លើយ ។

២-សុំសិទ្ធិអំណាចមេបា និងគ្រប់គ្រងកូនម្នាក់ឈ្មោះ [redacted] គីមឡាយ ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១២ ។

៣-សុំឱ្យចុងចម្លើយផ្ដល់អាហារកិច្ចចិញ្ចឹមកូនចំនួន ២០០ ដុល្លារ ក្នុងមួយខែ ។

៤-ទាមទារសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរួម មានដីផ្ទះទំហំ **៤ ម៉ែត្រ គុណ ១៨ ម៉ែត្រ** ដើម្បីទុកចិញ្ចឹមកូន ចំណែកឡានម៉ាក CRV ចំនួន ០១ គ្រឿង និងលុយចំនួន **២.០០០ (ពីរពាន់) ដុល្លារអាមេរិក** ប្រគល់ឱ្យចុងចម្លើយ ។

៥-សុំបែងចែកបំណុលរួម ចំនួន **៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក** ជាពីរចំណែក ។

#### ក.២ ខ្លឹមសារនៃសាលក្រមដែលដើមបណ្ដឹងតបទាមទារឱ្យតុលាការចេញ

១-សុំឈប់រស់នៅជាអនីតិសង្វាសពីប្រពន្ធឈ្មោះ [redacted] តាវ តាមការព្រមព្រៀង ។

២-កំណត់យកចុងចម្លើយឈ្មោះ [redacted] សុងហ៊ី ត្រូវជាឪពុក ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **គីមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ ។

៣-មិនទាមទារអាហារកិច្ចចិញ្ចឹមកូន ។

៤-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ដែលទ្រព្យសម្បត្តិរួមទាំងនោះមាន ៖

-ដី និងផ្ទះមួយល្វែង ទំហំ ០៤ **ម៉ែត្រ គុណ ២៤ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

-ដី និងផ្ទះមួយល្វែង ទំហំ ០៤ **ម៉ែត្រ គុណ ១៨ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិមិត្តភាព សង្កាត់ ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

៥-ចំពោះបំណុលប្រាក់ដុល្លារចំនួន **២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក** និងប្រាក់បាតចំនួន **២០០,០០០ (ម្ភៃម៉ឺន) បាត** ប្រគល់ឱ្យដើមចោទជាអ្នកទទួលរ៉ាប់រងសងទាំងអស់ ។

### ខ.ដំណើររឿងក្ដី និង ចំណុចវិវាទ

#### ខ.១ ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នាតាមប្រពៃណី តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់កំណត់ទេ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធអនីតិសង្វាស ដើមចោទ និងចុង

ប្ដីយមានកូនជាមួយគ្នាចំនួន ០៤ នាក់ ដែលក្នុងនោះមានកូនម្នាក់ដែលនៅជាអនីតិជននៅឡើយ ។ ដោយសារការរស់នៅមិនចុះសម្រុងជាមួយគ្នា ដើមចោទសម្រេចចិត្តដាក់ពាក្យបណ្ដឹងមកសាលាដំបូងខេត្តបន្ទាយមានជ័យ សុំផ្ដាច់អនីតិសង្វាសពីចុងចម្លើយ ហើយក្រោយមកចុងចម្លើយបានដាក់ពាក្យបណ្ដឹងតបទៅដើមចោទវិញ ដោយសារការអះអាងអំពីទ្រព្យសម្បត្តិរួម និងបំណុលរួម មិនត្រូវគ្នា និងទាមទារសិទ្ធិអំណាចមេបាលើកូនរៀងៗខ្លួន ។

**ខ.២ អង្គហេតុដែលគ្មានវិវាទ**

**ខ.២.១** ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយគ្នា តែពុំបានសុំចុះសំបុត្រអាពាហ៍ពិពាហ៍ជាប្ដីប្រពន្ធស្របតាមច្បាប់ដែលបានកំណត់ទេ ។

**ខ.២.២** គូភាគីអះអាងដូចគ្នាថា ការរស់នៅជាមួយគ្នា គឺមិនចុះសម្រុងនឹងគ្នា តែងតែឈ្លោះគ្នាជាញឹកញាប់ ធ្វើឱ្យអស់មនោសញ្ចេតនាមិនអាចបន្តរស់នៅជាមួយគ្នាបាន ។

**ខ.២.៣** គូភាគីអះអាងដូចគ្នាថា មានកូនបង្កើតជាមួយគ្នាចំនួន ០៤ នាក់ គឺ ៖

-កូនទី ១ ឈ្មោះ [redacted] **សុងហ៊ាន** ភេទប្រុស កើតថ្ងៃទី ០៨ ខែតុលា ឆ្នាំ១៩៩៥ មានសំបុត្របញ្ជាក់កំណើតលេខ ៨៩៧៨ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ។

-កូនទី ២ ឈ្មោះ [redacted] **មួយអ៊ាង** ភេទស្រី កើតថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧ មានសំបុត្របញ្ជាក់កំណើតលេខ ៨៩៧៩ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ។

-កូនទី ៣ ឈ្មោះ [redacted] **មួយឡាង** ភេទស្រី កើតថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០០ មានសំបុត្របញ្ជាក់កំណើតលេខ ៨៩៨០ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ។

-កូនទី ៤ ឈ្មោះ [redacted] **គីមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ មានសំបុត្របញ្ជាក់កំណើតលេខ ៣២៦ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ។

**ខ.៣ ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**ខ.៣.១ ចំណុចគ្មានវិវាទ**

១.គូភាគីយល់ព្រមក្នុងការផ្ដាច់អនីតិសង្វាស ។

២.គូភាគីយល់ព្រមក្នុងការផ្ដាច់អនីតិសង្វាស ។

៣.ទ្រព្យសម្បត្តិរួម ៖

-ដី និងផ្ទះមួយល្វែង ទំហំ ០៤ **ម៉ែត្រ គុណ ១៨ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិមិត្តភាព សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ **<u>គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា</u>** ។

-រថយន្ត ម៉ាក HONDA CRV ផ្លាកលេខ **បន្ទាយមានជ័យ ២A-៥១០០** ពណ៌ទឹកប្រាក់ **ផលិតឆ្នាំ ១៩៩៧ លេខម៉ាស៊ីន B20B42022608 <u>គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា</u>** ។

-ម៉ូតូចំនួន ០២ គ្រឿង រួមមាន ៖

+ម៉ាក ZOOMER X 110 ពណ៌ស ផ្លាកលេខ **កំពង់ស្ពឺ 1F-9548 លេខម៉ាស៊ីន JF62E-0125197 <u>ប្រគល់ទៅឱ្យដើមចោទជាកម្មសិទ្ធិ</u>** ។

+ម៉ាក HONDA CLICK ពណ៌ស ផ្លាកលេខ **សៀមរាប 1Y-7998** ផលិតឆ្នាំ ២០១៧ លេខម៉ាស៊ីន **CN125KE8023024 <u>ប្រគល់ទៅឱ្យចុងចម្លើយជាកម្មសិទ្ធិ</u>** ។

-លុយចំនួន **២,០០០ (ពីរពាន់)** ដុល្លារអាមេរិក **<u>គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា</u>** ។

### ខ.៣.១ ចំណុចវិវាទ

**១.**ការកំណត់សិទ្ធិអំណាចមេបាលើកូនម្នាក់ឈ្មោះ [redacted] **គីមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ និងការកំណត់ពីចំនួនប្រាក់សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ដែលជាករណីយកិច្ចរបស់ភាគីដែលមិនរស់នៅជាមួយកូនត្រូវទទួលបន្ទុក ។

**២.**តើដី និងផ្ទះមួយល្វែង ទំហំ **៤ ម៉ែត្រ គុណ ២៤ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាទ្រព្យសម្បត្តិរួមរវាងដើមចោទ និងចុងចម្លើយ ឬជាទ្រព្យសម្បត្តិដោយឡែក?

៣.តើបំណុលចំនួន **២០.០០០ (ពីរម៉ឺន) ដុល្លារ អាមេរិក** និងប្រាក់បាតចំនួន **២០០.០០០ (ម្ភៃម៉ឺន) បាត** ជាបំណុលរួមរវាងដើមចោទ និងចុងចម្លើយ ឬជាបំណុលដោយឡែក?

## គ.ភស្តុតាង

### គ.១ ភស្តុតាងដាក់បញ្ចូលដោយដើមចោទ

១.សំរង់សាលក្រមរដ្ឋប្បវេណីលេខ ៣៩ "ង" ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

២.លិខិតផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣ រវាងឈ្មោះ [redacted] **ចុងលាង** ផ្ទេរទៅឱ្យឈ្មោះ [redacted] **សឿន** និងប្រពន្ធឈ្មោះ [redacted] **សម្ភស្ស** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៣.លិខិតធានាអះអាង ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] **ចុងលាង** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៤.លិខិតបញ្ជាក់ព្រំប្រទល់ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] **ចុងលាង** ។ (ថតចម្លងចំនួន ០១ ច្បាប់) ។

៥.កិច្ចសន្យា ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] **ចុងលាង** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៦.លិខិតបញ្ជាក់អំពីប្រវត្តិដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥ របស់ឈ្មោះ ឈ្មោះ [redacted] **សឿន** និងប្រពន្ធឈ្មោះ [redacted] **សម្ភស្ស** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៧.លិខិតផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] **សឿន** និងប្រពន្ធឈ្មោះ [redacted] **សម្ភស្ស** ផ្ទេរទៅឱ្យឈ្មោះ [redacted] **សុងហ៊ី** និងប្រពន្ធឈ្មោះ [redacted] **គាវ** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៨.លិខិតធានាអះអាង និងកិច្ចសន្យា ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] **សឿន** និងប្រពន្ធឈ្មោះ [redacted] **សម្ភស្ស** ផ្ទេរទៅឱ្យឈ្មោះ [redacted] **សុងហ៊ី** និងប្រពន្ធឈ្មោះ [redacted] **គាវ** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៩.សៀវភៅគ្រួសារ លេខ ០៥០១៩ ក្បាលទី IV ទំព័រ ០៨៧ ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១២ ចេញដោយស្នងការនគរបាលខេត្តបន្ទាយមានជ័យ នាមត្រកូល-នាមខ្លួន ៖ [redacted] **សុងហ៊ី** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។



Scanned with CamScanner

១០.សំបុត្របញ្ជាក់កំណើតលេខ ៨៩៧៨ នៃសៀវភៅបញ្ជាក់កំណើតលេខ ៩៦/២០០៥ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ របស់ឈ្មោះ [redacted] **សុងប៉ាង** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

១១.សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតដែលចម្លងចេញពីសំបុត្របញ្ជាក់កំណើតលេខ ៨៩៧៩ នៃសៀវភៅបញ្ជាក់កំណើតលេខ ៩៦/២០០៥ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ របស់ឈ្មោះ [redacted] **មួយអ៊ាង** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

១២.សំបុត្របញ្ជាក់កំណើតលេខ ៨៩៨០ នៃសៀវភៅបញ្ជាក់កំណើតលេខ ៩៦/២០០៥ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ របស់ឈ្មោះ [redacted] **មួយឡាង** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

១៣.សំបុត្របញ្ជាក់កំណើតលេខ ៣២៦ នៃសៀវភៅបញ្ជាក់កំណើតលេខ ០៤/២០១៣ ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ របស់ឈ្មោះ [redacted] **គីមឡាយ** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

**គ.២ ឥស្សតាងដាក់បញ្ចូលដោយចុងចម្លើយ**

១.លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១០ រវាងឈ្មោះ [redacted] **សុភា** និងប្រពន្ធឈ្មោះ [redacted] **សុខលាភ** ផ្ទេរទៅឱ្យឈ្មោះ [redacted] **គាវ** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

២.លិខិតផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] **សឿន** និងប្រពន្ធឈ្មោះ [redacted] **សម្ផស្ស** ផ្ទេរទៅឱ្យឈ្មោះ [redacted] **សុងហ៊ី** និងប្រពន្ធឈ្មោះ [redacted] **គាវ** ។ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៣.កំណត់ហេតុអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៤.ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ៧៥ រកព/ង ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៥.កិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] **គីមហ្វយ** និងឈ្មោះ [redacted] **គាវ** ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៦.ពាក្យបណ្ដឹង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សាខាក្រុងប៉ោយប៉ែត ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៧.ដីកាសម្រេចរក្សាការពារលេខ ៤៨ រកព/ឆ ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៨.លិខិតផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន លេខ ៧៣ អប.រណ/ឆ ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៩.ពាក្យបណ្ដឹង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **អៀមស្រេង** ។ (ថតចម្លង ចំនួន ០១ ច្បាប់)



Scanned with CamScanner

# សំអាងហេតុ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ , មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ , ចុងចម្លើយ និងសហមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ នៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល និងបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការយល់ឃើញថា៖

## ក. ការវិនិច្ឆ័យអំពីការទាមទារ

**ក.១** ដើមចោទ បានដាក់ពាក្យបណ្តឹងសុំផ្តាច់អនីតិសង្វាសពីចុងចម្លើយ ស្របពេលដែលដើមចោទ និងចុងចម្លើយ មានអាសយដ្ឋានស្ថិតក្នុងខេត្តបន្ទាយមានជ័យ ។ **ឃើញថា** សាលាដំបូងខេត្តបន្ទាយមានជ័យ ជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងទាមទារនេះ អាចលើកយកមកវិនិច្ឆ័យចេញសាលក្រមបាន ។

ក.២ ការផ្សះផ្សារបស់តុលាការនៅគ្រប់នីតិវិធីពុំទទួលបានលទ្ធផល ដោយគូភាគីនៅតែមិនអាចសះជានឹងគ្នាបាន ។

ក.៣ ផ្អែកតាមអង្គហេតុដែលគ្មានវិវាទ និងចំណុចវិវាទ តុលាការទទួលស្គាល់ការទាមទារផ្តាច់អនីតិសង្វាសរបស់ដើមចោទ និងចុងចម្លើយ ដោយសារតែទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន ។ **ដូច្នេះហើយ គប្បីតុលាការពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ និងចុងចម្លើយទទួលស្គាល់នូវការទាមទារចំណុចទី ១ នៃពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨ របស់ដើមចោទ និងការទាមទារចំណុចទី ១ នៃខ្លឹមសារនៃសាលក្រមដែលទាមទារដោយ ចុងចម្លើយក្នុងបណ្តឹងតប ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០ របស់ចុងចម្លើយ ។**

ក.៤ អំពីកូន ៖

**ក.៤.១ ការកំណត់ពីសិទ្ធិអំណាចមេបា ÷** គូភាគីបានអះអាងដូចគ្នាថា មានកូនបង្កើតជាមួយគ្នាចំនួន ០៤ នាក់ ប៉ុន្តែកូនចំនួន ០៣ (បី) នាក់ បានក្លាយជានីតិជនអស់ហើយ មិនចាំបាច់ឱ្យតុលាការកំណត់អំពីសិទ្ធិអំណាចមេបាឡើយ ដោយឡែកកូនម្នាក់ឈ្មោះ [redacted] **គឹមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ គិតមកដល់ថ្ងៃចេញសាលក្រម មានអាយុ **០៨ ឆ្នាំ ០៦ ខែ និង ១៣ ថ្ងៃ** គឺស្ថិតនៅក្នុងភាពជាអនីតិជននៅឡើយ ចាំបាច់តុលាការត្រូវកំណត់អំពីសិទ្ធិអំណាចមេបាលើកូនដែលជាអនីតិជន ។ កូនដែលជាអនីតិជននេះ ត្រូវបានដើមចោទ និងចុងចម្លើយទាមទារសិទ្ធិអំណាចមេបាលើកូនរៀងៗខ្លួន ។ ដោយឡែកនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកទី ៣ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២០ ដែលមានវត្តមានរបស់ឈ្មោះ [redacted] **គឹមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ ដែលជាកូនបង្កើតរវាងដើមចោទ និងចុងចម្លើយបានចូលរួមក្នុងនីតិវិធីដែរ បានថ្លែងការណ៍ថា **"ខ្លួនចង់រស់នៅជាមួយប៉ា"** ដែលនេះគឺបញ្ជាក់ថា ឆន្ទៈរបស់កូនដែលគូភាគីទាមទារសិទ្ធិអំណាចមេបានោះ គឺចង់រស់នៅជាមួយភាគីចុងចម្លើយ **គប្បីតុលាការពិចារណា និងសម្រេចតាមឆន្ទៈរបស់កូន ។**

**ក.៤.២ ការកំណត់ពីប្រាក់សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ដែលជាករណីយកិច្ចរបស់ភាគីដែលមិនរស់នៅជាមួយ កូនត្រូវទទួលបន្ទុក ÷** គឺជាបន្ទុករបស់ដើមចោទ ព្រោះតាមឆន្ទៈរបស់ឈ្មោះ **លី គឹមឡាយ** ដែលជាកូនបង្កើត រវាងដើមចោទ និងចុងចម្លើយ គឺគាត់ចង់រស់នៅជាមួយចុងចម្លើយ បើទោះបីជាក្នុងពាក្យបណ្តឹងតបចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០ របស់ចុងចម្លើយត្រង់ **ខ្លឹមសារនៃសាលក្រមដែលទាមទារដោយ**

ចុងចម្លើយក្នុងពាក្យបណ្តឹងតប ចំណុចទី ៣ មានខ្លឹមសារថា "**មិនទាមទារអាហារកិច្ចចិញ្ចឹមកូន**" ក៏ដោយ ដោយតុលាការយល់ឃើញថា ដើម្បីជាផលប្រយោជន៍របស់កូនដែលជាអនីតិជន **គប្បីតុលាការពិចារណា និងសម្រេចឱ្យដើមចោទទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន ចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល ក្នុងមួយខែ ជារៀងរាល់ខែ ទៅឱ្យចុងចម្លើយ រហូតដល់កូនដែលជាអនីតិជនក្លាយទៅជានីតិជន** ។

**ក.៤.៣ ការកំណត់វិធីចូលជួប និងប្រាស្រ័យទាក់ទងកូន ដែលជាសិទ្ធិរបស់ភាគីដែលមិនរស់នៅជាមួយកូន** ៖ ដោយសារតែគូភាគីពុំបានពិភាក្សាគ្នាអំពីចំណុចនេះ ដូច្នេះតុលាការយល់ឃើញថា ដើម្បីផលប្រយោជន៍របស់កូន គប្បីតុលាការពិចារណា និងសម្រេចអំពីចំណុចនេះ ដូចខាងក្រោម ៖

-ក្នុង ០១ (មួយ) សប្តាហ៍ ចំនួន ០២ (ពីរ) ថ្ងៃ ៖ **នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ** ។

-រយៈពេលចូលជួបប្រាស្រ័យទាក់ទង ៖ ចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ (ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) គិតចាប់ពីម៉ោង **០៨ ព្រឹកនៃថ្ងៃសៅរ៍ រហូតដល់ម៉ោង ០៥ ល្ងាចនៃថ្ងៃអាទិត្យ** ។

-ទីកន្លែងដើម្បីចូលជួប និងប្រាស្រ័យទាក់ទងកូន ៖ ផ្ទះរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ឬទីកន្លែងណាផ្សេងទៀត តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **គារ** ។

+ទីកន្លែងប្រគល់-ទទួលកូន ៖ ផ្ទះរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ឬទីកន្លែងណាផ្សេងទៀត តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **គារ** ។

+អ្នកប្រគល់-ទទួលកូន ៖ ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **គារ** ឬ តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **គារ** ។

**ផ្អែកតាម សំអាងហេតុ ចំណុច ក.៤.១ និង ក.៤.២ នៃសាលក្រមនេះ គប្បីតុលាការពិចារណា និងសម្រេចច្រានចោលការទាមទារចំណុចទី ២ និងចំណុចទី ៣ នៃពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨ របស់ដើមចោទ និងការទាមទារចំណុចទី ៣ នៃខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយក្នុងបណ្តឹងតប ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០ របស់ចុងចម្លើយ ហើយទទួលស្គាល់នូវការទាមទារចំណុចទី ២ នៃខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយក្នុងបណ្តឹងតប ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០ របស់ចុងចម្លើយវិញ** ។

**ក.៥ អំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក** ៖ នៅក្នុងពាក្យបណ្តឹង , ពាក្យបណ្តឹងតប និងគ្រប់ដំណាក់កាលនៃនីតិវិធី ដើមចោទ និងចុងចម្លើយបានអះអាងអំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកផ្សេងពីគ្នា។ តាមរយៈការពិនិត្យភស្តុតាងនានាដែលបានដាក់បញ្ចូលដោយដើមចោទ និងចុងចម្លើយ និងតាម "**ចំណុចវិវាទ**" និង "**ចំណុចគ្មានវិវាទ**" ដែលតុលាការបានកំណត់ក្នុងសាលក្រមនេះ យល់ឃើញថា ទ្រព្យសម្បត្តិរបស់គូភាគីនៅក្នុងសំណុំរឿងនេះ គឺមានតែ "**ទ្រព្យសម្បត្តិរួម**" មានអត្តសញ្ញាណដូចខាងក្រោម ៖

**ក.៥.១** ដី និងផ្ទះមួយល្វែង ទំហំ ០៤ **ម៉ែត្រ គុណ ១៨ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិមិត្តភាព សង្កាត់ ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាន **លិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥** មានឈ្មោះដើមចោទ និងចុងចម្លើយជាម្ចាស់កម្មសិទ្ធិ **គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា** ។

ឥ.៥.២ រថយន្ត ម៉ាក HONDA CRV ផ្លាកលេខ **បន្ទាយមានជ័យ ២A-៥១០០** ពណ៌ទឹកប្រាក់ **ផលិតឆ្នាំ ១៩៩៧ លេខម៉ាស៊ីន B20B42022608** **<u>គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា</u>** ។

ឥ.៥.៣ ម៉ូតូចំនួន ០២ គ្រឿង រួមមាន ៖

-ម៉ាក ZOOMER X 110 ពណ៌ស ផ្លាកលេខ **កំពង់ស្ពឺ 1F-9548 លេខម៉ាស៊ីន JF62E-0125197** **<u>ប្រគល់ទៅឱ្យដើមចោទជាកម្មសិទ្ធិ</u>** ។

-ម៉ាក HONDA CLICK ពណ៌ស ផ្លាកលេខ **សៀមរាប 1Y-7998** ផលិតឆ្នាំ ២០១៧ លេខម៉ាស៊ីន CN125KE8023024 **<u>ប្រគល់ទៅឱ្យចុងចម្លើយជាកម្មសិទ្ធិ</u>** ។

ឥ.៥.៤ លុយចំនួន ២,០០០ (ពីរពាន់) ដុល្លារអាមេរិក **<u>គូភាគីយល់ព្រមក្នុងការបែងចែកជា ០២ ចំណែកស្មើគ្នា</u>** ។

ឥ.៥.៥ ចំពោះដី និងផ្ទះមួយល្វែង ទំហំ **៤ ម៉ែត្រ គុណ ២៤ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាន**លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១០** ដែលដើមចោទបានអះអាងថា ជា**ទ្រព្យសម្បត្តិដោយឡែក** តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១០ ដែលមានស្នាមមេដៃខ្លួនតែម្នាក់ដែលបានទិញលក់ដីនោះ ហើយគឺខ្លួនទិញដោយចំណាយប្រាក់ផ្ទាល់ខ្លួនពុំមានការចូលរួមប្រាក់ពីភាគីចុងចម្លើយឡើយ ចំណែកចុងចម្លើយអះអាងថា ជាទ្រព្យសម្បត្តិរួម ដោយផ្អែកលើដីនេះទិញក្នុងអំឡុងពេលដែលខ្លួន និងចុងចម្លើយបានរួមរស់ជាមួយគ្នាវិញជាប្តីប្រពន្ធ ហើយព្យាយាមរកស៊ីជាមួយគ្នាទើបសន្សំប្រាក់បានទិញដីនេះមក តែដោយសារពេលទិញដីគឺចុងចម្លើយរវល់រកស៊ីនៅក្នុងប្រទេសថៃ និងដោយសារយល់ឃើញថា ទោះមិនបានចុះឈ្មោះទិញដីរួមគ្នាក៏ដោយក៏នៅតែជាទ្រព្យប្តីប្រពន្ធ ទើបចុងចម្លើយពុំបានមកផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិដីធ្លី និងផ្ទះសម្បែងលើដី និងផ្ទះនេះ ។ តាមរយៈការអះអាងរបស់គូភាគី និងការពិនិត្យលើភស្តុតាងនានាក្នុងសំណុំរឿង <u>តុលាការឃើញថា</u> ទ្រព្យសម្បត្តិខាងលើជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ដោយសារដើមចោទ និងចុងចម្លើយបានរស់នៅអនីតិសង្វាសជាមួយគ្នា តាំងពីឆ្នាំ ២០០៧ មក ។ យោងតាមប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ “ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធសងខាង ឬ តែម្ខាងបានទទួលក្នុងអំឡុងពេលអាពាហ៍ពិពាហ៍” ដែលទ្រព្យនេះកើតឡើងពីការរកស៊ីជុំគ្នារវាងដើមចោទ និងចុងចម្លើយ ដូច្នេះទោះបីជាមានស្នាមមេដៃលើលិខិតផ្ទេរកម្មសិទ្ធិដីធ្លី និងផ្ទះសម្បែងនេះ របស់ដើមចោទតែម្ខាងក៏ដោយ តែដោយសារទ្រព្យសម្បត្តិនេះកើតឡើងពីការប្រកបរបរចិញ្ចឹមជីវិតរួមគ្នារវាងដើមចោទ និងចុងចម្លើយ **ហេតុដូច្នេះ គប្បីតុលាការពិចារណា និងសម្រេចបែងចែកទ្រព្យសម្បត្តិរួមនេះជា ០២ (ពីរ) ចំណែកស្មើគ្នាទៅឱ្យដើមចោទ និងចុងចម្លើយ** ។

ផ្អែកតាមសំអាងហេតុ ចំណុច ក.៥.១ , ក.៥.២ , ក.៥.៣ និង ក.៥.៤ នៃសាលក្រមនេះ ត្រូវបានគូភាគីព្រមព្រៀងគ្នាបែងចែកជា ២ ចំណែកស្មើគ្នាហើយ គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងនេះ និងយោងតាមសំអាងហេតុចំណុច ក.៥.៥ នៃសាលក្រមនេះ គប្បីតុលាការ ពិចារណា និងសម្រេចច្រានចោលការទាមទារចំណុចទី ៤ នៃពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨ របស់ដើមចោទ និងទទួលស្គាល់នូវការទាមទារចំណុចទី ៤ នៃ ខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយក្នុងបណ្តឹងតប ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២០ របស់ចុងចម្លើយ ។

**ក.៦ អំពីបំណុល ៖** តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលគូភាគីបានដាក់បញ្ចូលក្នុងសំណុំរឿង និងតាមសេចក្តីថ្លែងការណ៍របស់គូភាគី តុលាការពិនិត្យឃើញថា ទោះបីជាពុំមានភស្តុតាងជាឯកសារជាលិខិតលាយល័ក្ខណ៍អក្សរក្តី ព្រោះសកម្មភាពទិញលក់អាចធ្វើឡើងតាមរយៈផ្ទាល់មាត់ ដោយពុំបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរទេ ដែលដើមចោទ និងចុងចម្លើយសុទ្ធតែជាអ្នកប្រកបរបរជាអាជីវករទិញលក់សម្ភារៈ ដែលបញ្ជាក់ឱ្យឃើញថា បំណុលនេះជាបំណុលរួម ព្រោះកើតក្នុងអំឡុងពេលដែលគូភាគីរស់នៅជាអនីតិសង្វាស ហើយការកើតឡើងនៃបំណុលនេះ គឺដើម្បីរក្សាជីវភាពរួមប្តីប្រពន្ធ និងការអប់រំ មើលថែរក្សា និងចិញ្ចឹមកូនជាអាទិ៍ ព្រោះដើមចោទ និងចុងចម្លើយមានកូនបង្កើតជាមួយគ្នាចំនួន ០៤ នាក់ **ដូច្នេះហើយគប្បីតុលាការពិចារណា និងសម្រេចទទួលស្គាល់នូវទាមទារចំណុចទី ៤ នៃពាក្យបណ្តឹង ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨ របស់ដើមចោទ និងច្រានចោលការទាមទារចំណុចទី ៤ នៃ ខ្លឹមសារនៃសាលក្រមដែលទាមទារដោយចុងចម្លើយក្នុងបណ្តឹងតប ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២០ របស់ចុងចម្លើយ ។**

**ក.៧** ដោយសារតែដើមចោទជានារី បច្ចុប្បន្នពុំទាន់មានផ្ទៃពោះមុនពេលដែលអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយនេះត្រូវបានរំលាយ ដូច្នេះដើមចោទពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល **១២០ (មួយរយម្ភៃ) ថ្ងៃ** ពុំទាន់បានកន្លងផុត គិតចាប់ពីដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ គប្បីតុលាការពិនិត្យ និងសម្រេចដាក់ឱ្យដើមចោទស្ថិតនៅក្នុងភាពមេម៉ាយរយៈពេល **១២០ (មួយរយម្ភៃ) ថ្ងៃ** គិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

## ខ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ គប្បីតុលាការពិចារណា និងសម្រេចឱ្យគូភាគីទទួលបន្ទុកទៅតាមចំនួនទឹកប្រាក់ដែលសាមីខ្លួនបានបង់រួចហើយ ។

# សេចក្តីសម្រេចបញ្ចប់

**១-**ឱ្យដើមចោទឈ្មោះ [redacted] **តាវ** ភេទស្រី កើតថ្ងៃទី ២០ ខែមេសា ឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ និងចុងចម្លើយឈ្មោះ **ង្វួន សុងហ៊ី** ភេទប្រុស កើតថ្ងៃទី ១៥ ខែមីនា ឆ្នាំ១៩៧០ សញ្ជាតិខ្មែរ **ផ្តាច់អនីតិសង្វាសនឹងគ្នា** ។

**២-**ឱ្យចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** មានសិទ្ធិគ្រប់គ្រង និងសិទ្ធិអំណាចមេបាលើកូនឈ្មោះ **លី តីមឡាយ** ភេទប្រុស កើតថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១២ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ ។

**៣-**ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ត្រូវតែឱ្យឈ្មោះ [redacted] **តីមឡាយ** ដែលជាកូនរវាងដើមចោទ និងចុងចម្លើយចូលជួបប្រាស្រ័យទាក់ទងជាមួយដើមចោទឈ្មោះ [redacted] **តាវ** ដូចខាងក្រោម ៖

-ក្នុង ០១ (មួយ) សប្តាហ៍ ចំនួន **០២** (ពីរ) ថ្ងៃ ៖ **នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ** ។

-រយៈពេលចូលជួបប្រាស្រ័យទាក់ទង ៖ ចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ (ថ្ងៃសៅរ៍ និងថ្ងៃ អាទិត្យ) គិតចាប់ពីម៉ោង **០៨ ព្រឹកនៃថ្ងៃសៅរ៍ រហូតដល់ម៉ោង ០៥ ល្ងាចនៃថ្ងៃអាទិត្យ** ។

-ទីកន្លែងដើម្បីចូលជួប និងប្រាស្រ័យទាក់ទងកូន ៖ ផ្ទះរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ឬ ទីកន្លែងណាផ្សេងទៀត តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **តាវ** ។



Scanned with CamScanner

+ទីកន្លែងប្រគល់-ទទួលកូន ៖ ផ្ទះរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ឬទីកន្លែងណាផ្សេងទៀត តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **តារ** ។

+អ្នកប្រគល់-ទទួលកូន ៖ ចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **តារ** ឬ តាមការព្រមព្រៀងរបស់ចុងចម្លើយឈ្មោះ **ងួន សុងហ៊ី** និងដើមចោទឈ្មោះ [redacted] **តារ** ។

៤-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] **តារ** បង់ប្រាក់សោហ៊ុយដើម្បីថែរក្សាកូន **ចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល ក្នុងមួយខែ ជារៀងរាល់ខែ** ទៅឱ្យចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** គិតចាប់ត្រឹមថ្ងៃចុងក្រោយនៃខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះបានចូលជាស្ថាពរ រហូតដល់ឈ្មោះ [redacted] **តីមឡាយ** ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ ក្លាយទៅជានីតិជន ។

៥-បែងចែកទ្រព្យសម្បត្តិដូចខាងក្រោម ៖

**៥-១.បែងចែកជាពីរចំណែកស្មើគ្នាទៅឱ្យដើមចោទ និងចុងចម្លើយជាកម្មសិទ្ធិនូវ ៖**

-ដី និងផ្ទះមួយល្វែង ទំហំ **៤ ម៉ែត្រ គុណ ២៤ ម៉ែត្រ** មានទីតាំងស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាន**លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១០** ។

-ដី និងផ្ទះមួយល្វែង ទំហំ ០៤ ម៉ែត្រ គុណ ១៨ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិមិត្តភាព សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាន **លិខិតផ្ទេរកម្មសិទ្ធិកាន់កាប់ប្រើប្រាស់ដី ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥** ។

-រថយន្ត ម៉ាក HONDA CRV ផ្លាកលេខ **បន្ទាយមានជ័យ ២A-៥១០០ ពណ៌ទឹកប្រាក់ ផលិតឆ្នាំ ១៩៩៧ លេខម៉ាស៊ីន B20B42022608** ។

-លុយចំនួន **២,០០០ (ពីរពាន់) ដុល្លារអាមេរិក** ។

**៥-២.ប្រគល់ឱ្យជាកម្មសិទ្ធិនូវ ៖**

-ម៉ូតូ ម៉ាក ZOOMER X 110 ពណ៌ស ផ្លាកលេខ **កំពង់ស្ពឺ 1F-9548 លេខម៉ាស៊ីន JF62E-0125197 ទៅឱ្យដើមចោទឈ្មោះ** [redacted] **តារ** ។

-ម៉ូតូ ម៉ាក HONDA CLICK ពណ៌ស ផ្លាកលេខ **សៀមរាប 1Y-7998** ផលិតឆ្នាំ ២០១៧ លេខម៉ាស៊ីន **CN125KE8023024 ទៅឱ្យចុងចម្លើយឈ្មោះ** [redacted] **សុងហ៊ី** ។

**៦**-បែងចែកបំណុលរួម ចំនួន **៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក** ជាពីរចំណែកស្មើគ្នា ឱ្យដើមចោទឈ្មោះ [redacted] **តារ** និងចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ទទួលខុសត្រូវម្នាក់ពាក់កណ្តាល ។

៧-ច្រានចោលការទាមទារផ្សេងពីនេះ របស់ដើមចោទឈ្មោះ [redacted] **តារ** និងចុងចម្លើយឈ្មោះ [redacted] **សុងហ៊ី** ។

៨-ឱ្យដើមចោទឈ្មោះ [redacted] **តារ** ស្ថិតនៅក្នុងភាពជាមេម៉ាយ រយៈពេល **១២០ (មួយរយម្ភៃ) ថ្ងៃ** គិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

៩-ប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗជាបន្ទុករបស់ដើមចោទ និងចុងចម្លើយតាមចំណែកដែលសាមីខ្លួនបានបង់ ដែលប្រាក់នេះគូភាគីបានបង់រួចហើយ ។

សាលក្រមនេះ ត្រូវបានប្រកាស នៅសវនាការជាសាធារណៈ នៅថ្ងៃទី **២០ ខែមករា ឆ្នាំ២០២១** ។ ក្នុងករណីប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល **០១ ខែ** គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ថ្ងៃ ពុធ ០៧កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ ពុធ ០៧កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner